**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៦ សសរ

## សេចក្ដីសំរេច

## ស្ដីពី

## ការបន្ថែមភារៈកិច្ច និងសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវបាននាំយកទៅតាំងពិពណ៌ នៅប្រទេសជប៉ុន សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសាធារណរដ្ឋកូរ៉េ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋា-ភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញសេចក្ដីសំរេចស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យលើវត្ថុបុរាណសិល្បៈខ្មែរ លេខ ០៥ ស.ស.រ. ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០០៤
- យោងតាមតម្រូវការចាំបាច់ នៃការងារ

# សំរេច

**ប្រការ ១:** គណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលមានភារៈកិច្ចដូចដែលបានកំណត់ដោយសេចក្តីសំរេច លេខ ០៥ ស.ស.រ. ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៤ ត្រូវទទួលភារៈកិច្ចបន្ថែមលើការងារបច្ចុប្បន្ន ក្នុងការសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលក្រុមហ៊ុន CNK Bridge Company Co., Ltd. សាធារណរដ្ឋកូរ៉េ ខ្ចីយកទៅតាំងពិពណ៌នៅសាធារណរដ្ឋកូរ៉េ ពីថ្ងៃទី ២៨ ខែ មិថុនា ដល់ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤។

**ប្រការ ២:** ត្រូវបានបន្ថែមសមាជិក ចំនួន ២ រូប ទៀតក្នុងគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវបានខ្ចីយកទៅតាំងពិពណ៌នៅប្រទេសជប៉ុន សាធារណរដ្ឋសហពន្ធ័អាល្លឺម៉ង់ និង សាធារណរដ្ឋកូរ៉េ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក **សួស យ៉ារ៉ា** | តំណាងអាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |
| ២- លោក **ឡាយ ឆសាវុឌ្ឍ** | អនុប្រធាននាយកដ្ឋានស្ថាបនា ក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរ អប្សរា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ ដែលបានរាយនាមក្នុង ប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ